**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងកម្រិតបណ្តុះបណ្តាល និងប្រែក្លាយឈ្មោះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ព្រៃកូនខ្លា ទៅជា វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ០៩៥/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ព្រៃកូនខ្លា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្រែក្លាយ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ព្រៃកូនខ្លា ទៅជា «វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង» ឈ្មោះជាភាសាអង់គ្លេស «National Vocation Institute of Battambang» សរសេរជាអក្សរកាត់ជាភាសាខ្មែរ «វ.ជ.វ.ប» និងសរសេរជាអក្សរកាត់ជាភាសាអង់គ្លេស «N.V.I.B»។



www.pheakdeylaw.com

វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង ស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៥៧ ភូមិអណ្ដូងព្រីង សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

**មាត្រា ២.-**

វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង មានភារកិច្ចធ្វើការបណ្ដុះបណ្ដាល ៖

- កម្រិតវិញ្ញាបនបត្របណ្ដុះបណ្ដាលវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម ១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ និង៣ សិក្សារយៈពេល ១ឆ្នាំ ឬ ២ឆ្នាំ ឬ ៣ឆ្នាំ ដែលមានយ៉ាងតិច ៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស បរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

**មាត្រា ៣.-**

ចំពោះមុខ វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

១-ការិយាល័យរដ្ឋបាល និងបុគ្គលិក

២-ការិយាល័យផែនការ និងហិរញ្ញវត្ថុ

៣-ការិយាល័យធានាគុណភាព និងយេនឌ័រ

៤-បណ្ណាល័យ

៥-ការិយាល័យអប់រំបណ្ដុះបណ្ដាល

៦-ការិយាល័យអភិវឌ្ឍន៍កម្មវិធីសិក្សា និងទំនាក់ទំនងឧស្សាហកម្ម

៧-ដេប៉ាតឺម៉ង់វិស្វកម្មសំណង់ស៊ីវិល និងអភិវឌ្ឍន៍គ្រឹះស្ថាន

៨-ដេប៉ាតឺម៉ង់រថយន្ត និងគ្រឿងយន្តកសិកម្ម

៩-ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា

១០-ដេប៉ាតឺម៉ង់ក្សេត្រសាស្ត្រ

១១-ដេប៉ាតឺម៉ង់វារីវប្បកម្ម

១២-ដេប៉ាតឺម៉ង់បសុព្យាបាល

នៅថ្ងៃអនាគត វិទ្យាស្ថានអាចបើកដេប៉ាតឺម៉ង់ ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**មាត្រា ៤.-**

លក្ខខណ្ឌទទួលសិស្ស-និស្សិតឱ្យចូលរៀន ៖

- កម្រិតវិញ្ញាបនបត្របណ្ដុះបណ្ដាលវិជ្ជាជីវៈ៖ បេក្ខជនជាសិក្ខាកាម សិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១៖ បេក្ខជនបានរៀនចប់ថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ ឬវិញ្ញាបនបត្រស្ពានចម្លងបន្តជំនាញ ឬវិញ្ញាបនបត្រដែលមានតម្លៃស្មើ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២៖ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣៖ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស បរិញ្ញាបត្ររង៖ បេក្ខជនដែលប្រឡងជាប់ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ៖ បេក្ខជនមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ



www.pheakdeylaw.com

សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស បរិញ្ញាបត្ររង ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**មាត្រា ៥.-**

នាយកនៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង មានបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ៦.-**

វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង កាន់កាប់ និងប្រើប្រាស់ប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវឧបត្ថម្ភដោយថវិកាជាតិសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានគណនេយ្យដោយឡែក។

**មាត្រា ៧.-**

សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាន ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រដែលផ្តល់ឱ្យដោយវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបងនឹងត្រូវទទួល ស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាម គោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ នាយកវិទ្យាស្ថាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com